ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
នាយកដ្ឋានសវនកម្មផ្ទៃក្នុង
លេខ...០៧៦...ន.សផក

ច្បាប់ លេខ 3060 ថ្ងៃ 23.5.24

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខុទ្ទកាល័យ ច្បាប់ លេខ 2251 ថ្ងៃទី 20.05.24

ថ្ងៃចន្ទ ១៣កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤

**សូមគោរពជូន**
**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**កម្មវត្ថុ:** អំពីរបាយការណ៍សវនកម្មនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ចាម

**យោង:**
- សេចក្តីជូនដំណឹងលេខ១២០ ដនស/នា.សផក ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ ស្តីពីការអនុវត្តផែនការសវនកម្ម និងផែនការតាមដានអនុសាសន៍ប្រចាំឆ្នាំ២០២៤ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតបញ្ជាបេសកកម្មលេខ១២០៦ ដនស ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតបញ្ជាបេសកកម្មលេខ១២០៧ ដនស ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមអនុញ្ញាតគោរពជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា របាយការណ៍សវនកម្មផ្ទៃក្នុងនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ចាម ជារបាយការណ៍អនុវត្តតាមគំរូស្តង់ដារបាយការណ៍សវនកម្ម របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឱ្យគ្រប់ក្រសួង-ស្ថាប័នអនុវត្តតាម ហើយរបាយការណ៍នេះក៏នឹងត្រូវផ្ញើជូន អាជ្ញាធរសវនកម្មជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ។

ឆ្លងតាមការធ្វើសវនកម្មបានបង្ហាញឱ្យឃើញថា ការគ្រប់គ្រង និងប្រើប្រាស់ថវិកា មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ចាមសម្រាប់ការិយបរិច្ឆេទឆ្នាំ២០២៣ មានចំណុចល្អមួយចំនួនដូចជា÷

- កិច្ចបញ្ជិកា ការរៀបចំរក្សាឯកសារគណនេយ្យ ឯកសាររណប និងការកត់ត្រាមានសណ្តាប់ធ្នាប់ល្អជាងឆ្នាំកន្លងមក។
- ការអនុវត្តតាមអនុសាសន៍ដែលប្រតិភូសវនកម្មផ្ទៃក្នុងបានផ្តល់ជូនសម្រាប់ការិយបរិច្ឆេទកន្លងមកបានល្អប្រសើរ។

**ទន្ទឹមនឹងនោះ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ចាម ក៏នៅមានចំណុចខ្វះខាតមួយចំនួនដូចជា÷**

**១-ការអនុវត្តការងារសំណង់**

-បណ្តាការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក មិនបានបញ្ជូនឯកសារលិខិតអនុញ្ញាតសាងសង់សំណង់ មកការិយាល័យសំណង់របស់មន្ទីរ។

**២- ការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ**

-មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ចាម ពុំមានបំពាក់ប្រព័ន្ធការពារអគ្គិភ័យនៅក្នុងបន្ទប់ម៉ាស៊ីនមេ (Server) និងឃ្លាំងទុកដាក់រក្សាឯកសារសុរិយោដី។

**៣- ការងារសុរិយោដី និងភូមិសាស្ត្រ និងកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី**

-ពីឆ្នាំ២០១២ រហូតដល់បច្ចុប្បន្ន មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ចាមមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលវត្ថុដែលខូចចំនួន **២៣,៨៣៣** សន្លឹក។

**ប្រតិភូសវនកម្មបានផ្តល់អនុសាសន៍កែលម្អដូចខាងក្រោម÷**

១-មន្ទីរត្រូវជំរុញការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុកទាំងអស់ បញ្ជូននូវសំណុំឯកសារលិខិតអនុញ្ញាតសាងសង់សំណង់ មកការិយាល័យសំណង់របស់មន្ទីរ នៅពេលដែលម្ចាស់សំណង់បានសុំការអនុញ្ញាតរួចរាល់។

២-នៅក្នុងបន្ទប់ម៉ាស៊ីនមេ(Server) និងឃ្លាំងទុកដាក់រក្សាឯកសារសុរិយោដី មន្ទីរត្រូវបំពាក់ប្រព័ន្ធការពារអគ្គិភ័យជាបន្ទាន់។

៣-មន្ទីរត្រូវធ្វើបច្ចុប្បន្នភាពសន្លឹកបណ្ណខូច រួចហើយស្នើសុំបង្កើតគណៈកម្មការត្រួតពិនិត្យសន្លឹកបណ្ណខូច និងបូកសរុប ដើម្បីដុតកម្ទេច ស្របតាមលិខិតលេខ៣២៩ អ/សដភ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រងសន្លឹកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាប និងមានមតិដឹកនាំ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពពីខ្ញុំបាទ។

**ប្រធាននាយកដ្ឋាន**

**យួន_សុជាតិ**

| **មតិឯកឧត្តមរដ្ឋលេខាធិការប្រចាំការ** | **មតិឯកឧត្តមប្រធានក្រុមការងារ** |
| --- | --- |
| 20.05.24 | |

**មតិសម្រេចឯកឧត្តមឧបនាយករដ្ឋមន្ត្រី**